ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ...ធ៧...០៦...១២០...ប្រក

# ប្រកាស

## ស្ដីពីការកែសម្រួលប្រកាសស្ដីពី សោហ៊ុយបង្កើនដើមទុនសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាស អោយប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧៩៧-១៤៧ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីល័ក្ខខ័ណ្ឌសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦

## ស ំ រ េ ច

**ប្រការមួយ.-**

កែសម្រួល ចំណុច ៣.២ ប្រការ ៣ នៃប្រកាសលេខធ៧៩៧-១៤៧ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីល័ក្ខខ័ណ្ឌសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានដូចខាងក្រោម ៖

**ប្រការ៣ថ្មី.-**

៣.២ថ្មី.រាល់ការបង្កើនដើមទុន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ជាមុន។ ការបង្កើនដើមទុនត្រូវបង់សោហ៊ុយចំនួនសូន្យក្បៀសសូន្យបីភាគរយ (០,០៣%) លើចំនួនប្រាក់ដែលសុំបង្កើន ។

**ប្រការ៣.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៤.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ ២០០៦

**អភិបាល**

**ជា-ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA

NATION RELIGION KING

NATIONAL BANK OF CAMBODIA

Unofficial Translation

Number B7.06-210 Prkor.

# PRAKAS
## on
## Amendment to Prakas on Fee for Increase of Capital of Banks and Financial Institutions

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244 of 7 September 2004 on the appointment of His Excellency **Chea Chanto** as Governor of the National Bank of Cambodia, as equivalent to Senior Minister;
- With reference to the PRAKAS No B797-147 Pro Kor on Conditions for Banks and Financial institutions on December 29, 2006,
- Pursuant to the recommendation made by the National Bank of Cambodia management during the September 04, 2006, meeting.

## DECIDES

**Article One**

Amendment to Section 3.2 of Article3 of the Prakas No B797-147 Pro Kor on Conditions for Banks and Financial institutions on December 29, 2006, as follows:

**New Article 3**

New Section 3.2.Banks and Financial Institutions shall seek permission from the National Bank of Cambodia prior to the increase of capital. Each increase of capital is subject to a processing fee of 0.03% of the increased amount.

**Article Two**

The General Directorate, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking and

Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article Three**

This Prakas shall have effect from the signing date.

Phnom Penh, September 13, 2006

**The Governor**

**Signed and sealed: Chea Chanto**

cc.

- The parties concerned as stated in Article Two
- File
- The Members of the Board of Directors
- CM "for info"
- Administration of CM "for publication in the National Gazette"